# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រម

២១-១០-២០០៦ -ព្រះរាជក្រម នស/រកម/១០០៦/០២៦ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពី ឯកពន្ធភាព ៧១៥៤

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

២៦-១០-២០០៦ -អនុក្រឹត្យលេខ ១១៥ អនក្រ.បក ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទ ៧១៦០

២៦-១០-២០០៦ -អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ៧១៧០

២៧-១០-២០០៦ -អនុក្រឹត្យលេខ ១១៧ អនក្រ.បក ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៧ ៧១៧៨

២៦-១០-២០០៦ -អនុក្រឹត្យលេខ ៦៩៦ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយទាហាន ៧១៨០

២៧-១០-២០០៦ -អនុក្រឹត្យលេខ ៦៩៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧១៨៨

២៧-១០-២០០៦ -អនុក្រឹត្យលេខ ៦៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧១៨៩

២៧-១០-២០០៦ -អនុក្រឹត្យលេខ ៦៩៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧១៩០

២៧-១០-២០០៦ -អនុក្រឹត្យលេខ ៧០០ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៧១៩១

### ២-សេចក្តីសម្រេច

២៧-១០-២០០៦ -សេចក្តីសម្រេចលេខ ៤៦ សសរ ស្តីពីការបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ភ្នំពេញ ៧១៩៣

២៩-១០-២០០៦ -សេចក្តីសម្រេចលេខ ៤៧ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៧១៩៦

## III-ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៧-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វាហ្សា ម៉ីអូតិច (ខេមបូឌា) ខូ អិលធីឌី** ៧១៩៧

| | | |
|---|---|---|
| ១៧-៨-២០០៦ | -លិខិតបញ្ជាក់លេខ ២១០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មាស ឌីវេឡុបមេន ខូ អិលធីឌី** | ៧១៩៩ |
| ១៧-៨-២០០៦ | -លិខិតបញ្ជាក់លេខ ២១០៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្ទីលូស អុីមផត អិចផត ខូ អិលធីឌី** | ៧២០១ |
| ១៧-៨-២០០៦ | -លិខិតបញ្ជាក់លេខ ២១១០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃែរី ឡូជីស្ទីក (ខេមបូឌា) ភីធីអុី អិលធីឌី** | ៧២០៣ |
| ១៧-៨-២០០៦ | -លិខិតបញ្ជាក់លេខ ២១១១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អុីលែនអាគ្រោភ្លាថេក (ខេមបូឌា)** | ៧២០៥ |
| ១៧-៨-២០០៦ | -លិខិតបញ្ជាក់លេខ ២១១២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថាន់ ឈៀ (ខេមបូឌា)** | ៧២០៧ |
| ១៧-៨-២០០៦ | -លិខិតបញ្ជាក់លេខ ២១១៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រស្មី សុវណ្ណភូមិ** | ៧២០៩ |
| ១៧-៨-២០០៦ | -លិខិតបញ្ជាក់លេខ ២២២៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាន់តារា អុិនធើណេសិនណល** | ៧២១១ |
| ៣១-៨-២០០៦ | -លិខិតបញ្ជាក់លេខ ២២៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គង់លីលី គ្រុប** | ៧២១៣ |
| ៣១-៨-២០០៦ | -លិខិតបញ្ជាក់លេខ ២២៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មីតស្នារ៉ា (ខេមបូឌា)** | ៧២១៥ |
| ៣១-៨-២០០៦ | -លិខិតបញ្ជាក់លេខ ២២៣៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន **ស៊ិដភូ ហ្វ៊ីរិច អុិនធើណេសិនណល អុិន** | ៧២១៧ |
| ៣១-៨-២០០៦ | -លិខិតបញ្ជាក់លេខ ២២៣៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌ) សុវណ្ណថា អុិនវេសមេន** | ៧២១៨ |

# ព្រះរាជក្រម

នស/រកម/១០០៦/០២៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរជនា សមូហោភាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ឯកពន្ធភាព ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ឯកពន្ធភាព

:/6ɑ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលបំណងការពារសេចក្តីថ្លៃថ្នូរ និងពង្រឹងសុខដុមរមនា សុភមង្គលក្នុងគ្រួសារ និងការគោរពសិទ្ធិគ្នាទៅវិញទៅមករវាងប្តីនិងប្រពន្ធ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា ២.–**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវគោរពគោលការណ៍ឯកពន្ធភាពដោយស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ដោយមានចុះបញ្ជីអាពាហ៍ពិពាហ៍ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

## ជំពូកទី ២
## និយមន័យ ពិរុទ្ធភាព និងនីតិវិធី

**មាត្រា ៣.–**

ឯកពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ ដែលបុរសមានប្រពន្ធតែមួយ ឯស្ត្រីមានប្តីតែមួយ ។ ដែលហៅថាចំណងអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាថារួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន ។

ចំណងអាពាហ៍ពិពាហ៍ត្រូវរលាយក្នុងករណីណាមួយដូចខាងក្រោម :

-សហព័ទ្ធណាមួយស្លាប់ ។

-មានសេចក្តីសម្រេចរំលាយចំណងអាពាហ៍ពិពាហ៍ជាស្ថាពររបស់តុលាការ ។

-សហព័ទ្ធណាម្នាក់បាត់ខ្លួនហួសពីមួយឆ្នាំដោយគ្មានដំណឹងអ្វីសោះ មិនដឹងថាស្លាប់ ឬរស់ ។

4

16.

**មាត្រា ៤.-**

ទ្វេពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ដែលបុរសមានប្រពន្ធពីរ ឯស្ត្រីមានប្ដីពីរ ។

ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទទ្វេពន្ធភាព បុរស ឬ ស្ត្រីណាដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយនៅឡើយ ហើយទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត ។

អ្នកសមគំនិតត្រូវមានទោសដូចគ្នា ។

**មាត្រា ៥.-**

ត្រូវចាត់ទុកថាស្ទន់ បុរស និងស្ត្រីណាដែលជាប់ចំណងជាញាតិលោហិត ឬ ញាតិពន្ធនឹងគ្នា ហើយរួមសេវនកិច្ចជាមួយគ្នា ។

**មាត្រា ៦.-**

ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទស្ទន់ :

-បុរស និងស្ត្រីដែលជាប់ចំណងជាញាតិលោហិត ឬ ញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះចំណងនោះមានខាន់ស្លាក្ដី ឥតខាន់ស្លាក្ដី ឬ ជាសាច់ចិញ្ចឹមក្ដី បានរួមសេវនកិច្ចជាមួយគ្នា ។

-បុរស និងស្ត្រីដែលជាប់ចំណងសាខាញាតិនឹងគ្នា ទោះសាខាញាតិនោះមានខាន់ស្លាក្ដី ឥតខាន់ស្លាក្ដី ចិញ្ចឹមក្ដី រួមម្ដាយក្ដី រួមឪពុកក្ដី រួមម្ដាយឪពុកក្ដី ជាញាតិលោហិតក្ដី ឬ ជាញាតិពន្ធក្ដី រហូតដល់ថ្នាក់ទី ៣ រាប់ទាំងថ្នាក់នេះ ផងបានរួមសេវនកិច្ចជាមួយគ្នា ។

មិនចាត់ទុកថាមានពិរុទ្ធពីបទស្ទន់ទេ ប្រសិនបើសហព័ទ្ធណាម្នាក់ស្លាប់ ហើយសហព័ទ្ធដែលនៅរស់រួមសេវនកិច្ចជាមួយសាខាញាតិពន្ធថ្នាក់ទី ២ ឬ ថ្នាក់ទី ៣ ។

**មាត្រា ៧.-**

ត្រូវចាត់ទុកថាផិត គឺការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្ដីរបស់ខ្លួន ។

ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទផិត :

-បុរសណា ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ហើយទៅរួមសេវនកិច្ចជាមួយស្ត្រីផ្សេងទៀត ។

-ស្ត្រីណា ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ហើយទៅរួមសេវនកិច្ចជាមួយបុរសដទៃទៀត ។

**មាត្រា ៨.-**

ក្នុងករណីដែលមានចែងក្នុងមាត្រា ៧ ខាងលើ ព្រះរាជអាជ្ញាអាចសំរេចមិនធ្វើបណ្តឹងអាជ្ញាបាន ប្រសិនបើមានបណ្តឹងរបស់សហព័ទ្ធណាមួយស្នើសុំកុំឱ្យចោទប្រកាន់ ។

## ជំពូកទី ៣
## ទោសប្បញ្ញត្តិ

**មាត្រា ៩.-**

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ដល់ ១ (មួយ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០.០០០ (ពីររយពាន់) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល ឬ ផ្តន្ទាទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ១០.-**

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៦ និងមាត្រា ៧ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ដល់ ១ (មួយ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០.០០០ (ពីររយពាន់) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល ឬ ផ្តន្ទាទោសណាមួយនៃទោសទាំងពីរ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

ច្បាប់នេះ ពុំមានអានុភាពប្រតិសកម្មឡើយ ។

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.១០០៦/០៤២ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ:៤០១ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១១៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពដាច់ពីគេនៃកងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ ០៧ /នស/៩៤ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក. ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់លក្ខខណ្ឌនៃការចូលនិវត្តន៍តាមការកំណត់ ការចូលនិវត្តន៍មុនពេលកំណត់ និងលក្ខខណ្ឌនៃការទទួលរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទ សំដៅអនុវត្តច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ និងច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២.-** ដើម្បីអនុវត្តអនុក្រឹត្យនេះ ពាក្យដូចខាងក្រោម ត្រូវកំណត់និយមន័យដូចតទៅ :

- របបសោធននិវត្តន៍ គឺជាគោលរបបគិតជាទឹកប្រាក់ ដែលរដ្ឋត្រូវផ្តល់អោយយោធិនម្នាក់ៗ ដែលបានបំពេញតាមលក្ខខណ្ឌចូលនិវត្តន៍ និងរយៈពេលបំរើការងារ ។

- របបបាត់បង់សមត្ថភាពការងារ គឺជាគោលរបបគិតជាទឹកប្រាក់ ដែលរដ្ឋត្រូវផ្តល់អោយយោធិនម្នាក់ៗ ផ្អែកតាមសកម្មភាពបំពេញការងាររបស់ខ្លួនកន្លងមក មានផលប៉ះពាល់សុខភាព ដោយមិនអាចបន្តការងារទៀតបាន ហើយត្រូវបានចាត់ចូលក្នុង ប្រភេទបាត់បង់សមត្ថភាពការងារ ។

- របបចេញពីជួរ គឺជាទឹកប្រាក់ដែលត្រូវផ្តល់អោយយោធិនណាដែលបានបញ្ចប់ភារកិច្ចជាយោធិនអាជីព ហើយមិនបានបំពេញគ្រប់លក្ខខណ្ឌចូលនិវត្តន៍ និងមិនត្រូវបានចាត់ចូលក្នុងប្រភេទបាត់បង់សមត្ថភាពការងារ ។

## ជំពូកទី២

## របបសោធននិវត្តន៍

**មាត្រា៣.-**

យោធិនអាជីព អាចចូលនិវត្តន៍បានតាមការកំណត់ លុះត្រាតែបានបំពេញលក្ខខណ្ឌដូចខាងក្រោម÷

**ក-នាយទាហាន :**

| | | |
|---|---|---|
| ១-ថ្នាក់វរសេនីយ៍ឯក | និងវរនាវីឯកឡើងទៅ | នៅពេលដល់អាយុ ៦០ ឆ្នាំ |
| ២-ថ្នាក់វរសេនីយ៍ទោ | និងវរនាវីទោ | នៅពេលដល់អាយុ ៥៨ ឆ្នាំ |
| ៣-ថ្នាក់វរសេនីយ៍ត្រី | និងវរនាវីត្រី | នៅពេលដល់អាយុ ៥៥ ឆ្នាំ |
| ៤-ថ្នាក់អនុសេនីយ៍ឯក | និងអនុនាវីឯក | នៅពេលដល់អាយុ ៥៣ ឆ្នាំ |

| | | |
|---|---|---|
| ៥-ថ្នាក់អនុសេនីយ៍ទោ | និងអនុនាវីទោ | នៅពេលដល់អាយុ ៤៨ ឆ្នាំ |
| ៦-ថ្នាក់អនុសេនីយ៍ត្រី | និងអនុនាវីត្រី | នៅពេលដល់អាយុ ៤៦ ឆ្នាំ |
| ៧-ថ្នាក់នាយចំណង់ | និងនាយនាវីចំណង់ | នៅពេលដល់អាយុ ៤៣ ឆ្នាំ |

**ខ-នាយទាហានរង :**

| | | |
|---|---|---|
| ១-ថ្នាក់ព្រិន្ទបាលឯក | និងនាយចក្របាលឯក | នៅពេលដល់អាយុ ៤២ ឆ្នាំ |
| ២-ថ្នាក់ព្រិន្ទបាលទោ | និងនាយចក្របាលទោ | នៅពេលដល់អាយុ ៤១ ឆ្នាំ |
| ៣-ថ្នាក់ពលបាលឯក | និងចក្របាលឯក | នៅពេលដល់អាយុ ៤០ ឆ្នាំ |
| ៤-ថ្នាក់ពលបាលទោ | និងចក្របាលទោ | នៅពេលដល់អាយុ ៣៩ ឆ្នាំ |
| ៥-ថ្នាក់ពលបាលត្រី | និងចក្របាលត្រី | នៅពេលដល់អាយុ ៣៨ ឆ្នាំ |

**មាត្រា៤.-**

យោធិនអាជីពដែលចូលនិវត្តន៍បានតាមការកំណត់ ដូចមានចែងក្នុងជំពូកទី២ មាត្រា៣ នៃអនុក្រឹត្យនេះ អាចទទួលរបបសោធននិវត្តន៍បាន លុះត្រាតែបានបំពេញគ្រប់លក្ខខណ្ឌរយៈពេលបំរើការងារ ដូចមានចែងក្នុងមាត្រា២ថ្មី នៃច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា៥.-**

យោធិនអាជីព អាចចូលនិវត្តន៍បានមុនពេលកំណត់ ដោយមិនគិតពីលក្ខខណ្ឌឋានន្តរសក្តិ មិនគិតពីលក្ខខណ្ឌអាយុ អាចទទួលរបបសោធននិវត្តន៍បាន លុះត្រាតែបានបំពេញគ្រប់លក្ខខណ្ឌរយៈពេលបំរើការងារ ដូចមានចែងក្នុងមាត្រា២ថ្មី ចំណុច ក (១-២) នៃច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា៦.-**

យោធិនអាជីព ដែលមិនបានទទួលរបបសោធននិវត្តន៍ ជាយោធិនមានគ្រប់លក្ខខណ្ឌឋានន្តរសក្តិ មានគ្រប់លក្ខខណ្ឌអាយុ តែមិនបានបំពេញគ្រប់លក្ខខណ្ឌរយៈពេលបំរើការងារ ត្រូវទទួលបានរបបចេញពីជួរ ដោយទទួលប្រាក់ឧបត្ថម្ភផ្តាច់សរុបមួយ ស្មើនឹងបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួន គុណនឹងចំនួនឆ្នាំនៃរយៈពេលបំរើការងារ ប៉ុន្តែចំនួនទឹកប្រាក់នេះ មិនត្រូវតិចជាង ៦ខែ នៃបៀវត្សសរុបចុងក្រោយរបស់សាមីខ្លួនឡើយ ។

**មាត្រា៧.-**

របៀបគិតរយៈពេលបំរើការងារ ព្រមទាំងកំណត់តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព

របស់យោធិនម្នាក់ៗ ត្រូវបានកំណត់ដូចខាងក្រោម ÷

**១_របៀបគិតរយៈពេលបំពេញការងារ :**

ការគិតរយៈពេលបំរើការងារ គឺបានគិតរួមទាំងរយៈពេលបំរើការងារគ្រប់របបសង្គម "បើមាន" និងរយៈពេលបំរើការងារស៊ីវិល និងកងយោធពលខេមរភូមិន្ទដោយ :

**ក-ត្រូវចាត់ទុកជារយៈពេលបំរើការងារ :**

ការចាត់ទុកជារយៈពេលបំរើការងារ គឺគិតចាប់តាំងពីមន្ត្រីរាជការ បុគ្គលិក កម្មកររដ្ឋ ដែលបានបញ្ចូលទៅក្នុងក្របខណ្ឌ "រដ្ឋពេញសិទ្ធិ" រួចក្រោយមក ចូលបំរើក្នុងកងយោធពលខេមរភូមិន្ទ ឬចាប់ពីពេលចូលបំរើក្នុងកងយោធពលខេមរភូមិន្ទជាប់រហូត ដល់ពេលចូលនិវត្តន៍ ។ ស្ថានភាពនៃរយៈពេលបំរើការងារ ត្រូវបានគិតដូចខាងក្រោម ÷

-រយៈពេលធ្វើរដ្ឋបាល ភូមិ ឃុំ សង្កាត់ ឬកងជីវពល ដែលមានប្រាក់ឧបត្ថម្ភ

-រយៈពេលមន្ត្រីរាជការ បុគ្គលិក កម្មកររដ្ឋ ធ្វើការតាមក្រសួង ស្ថាប័នរដ្ឋនានា ឬរយៈពេលទៅធ្វើកម្មសិក្សាក្នុង ឬក្រៅប្រទេស

-រយៈពេលមន្ត្រីរាជការ ធ្វើការងារក្រៅប្រទេស

-រយៈពេលបំរើការងារអតីតភាពតាមរបបសង្គម

-រយៈពេលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទ

-រយៈពេលជាប់មន្ទីរឃុំឃាំង ដោយគ្មានទោសកំហុស

-រយៈពេលដែលយោធិនស្ថិតក្នុងកិច្ចសន្យា ។

**ខ-មិនត្រូវចាត់ទុកជារយៈពេលបំរើការងារ :**

-គឺជារយៈពេល ដែលតម្រូវអោយមន្ត្រីរាជការ បុគ្គលិក កម្មកររដ្ឋ ធ្វើការសាកល្បង ។

**២_ការកំណត់តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ដូចជា :**

តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ត្រូវបានកំណត់ដូចខាងក្រោម ÷

**ក-តំបន់លំបាក :**

យោធិនបានបំពេញភារកិច្ចនៅតំបន់ដាច់ស្រយាល ឬកោះ តំបន់គ្រុនចាញ់ តំបន់ព្រៃភ្នំ លំបាកដោយអាកាសធាតុ ឬលំបាកដោយជីវភាពរស់នៅ និងសមរភូមិប្រយុទ្ធ ។

**ខ-ការងារគ្រោះថ្នាក់ :**

យោធិនជាអាកាសយានិក ទ័ពជំនាញឆ័ត្រយោង ទ័ពវិស្វកម្ម ជំនាញដោះមីន ទ័ពជំនាញផលិត ឬពិសោធន៍គ្រឿងផ្ទុះ។

**គ-ការងារប៉ះពាល់សុខភាព :**

យោធិនជានាវិក ជាងផ្សារដែក ជាងជួសជុលគ្រឿងចក្រធុនធ្ងន់ បុគ្គលិកកាំជា ជាងអគ្គិសនី

អ្នកធ្វើការងារនៅអាគារជម្ងឺឆ្លង អាគារថតឆ្លុះ និងមន្ទីរពិសោធន៍ មន្ទីរពេទ្យ ទ័ពជំនាញគីមីសាស្ត្រ ជំនាញកាំភ្លើងធំ អ្នកបើកបរគ្រឿងចក្រធុនធ្ងន់ ។

ដើម្បីអនុវត្តឱ្យបានល្អ និងមានប្រសិទ្ធភាពនោះ ក្រសួងការពារជាតិត្រូវធ្វើប្រកាស កំណត់លំអិតអំពីលក្ខខណ្ឌជាក់ស្តែង ។

**មាត្រា៨.-**

ប្រាក់សោធននិវត្តន៍រួមមាន បៀវត្សរ៍ឋានន្តរសក្តិ ត្រូវបានបូកបន្ថែមជាមួយប្រាក់ឧបត្ថម្ភលើបៀវត្សរ៍ឋានន្តរសក្តិ បូកប្រាក់ហូបប្រចាំខែ បូកប្រាក់បំណាច់មុខងារ "បើមាន" បូកប្រាក់បំណាច់តំបន់ "បើមាន" ។

**មាត្រា៩.-**

យោធិនអាជីព ដែលមានគ្រប់លក្ខខណ្ឌ ត្រូវបានទទួលរបបសោធននិវត្តន៍ជាប្រចាំខែ ដូចមានចែងក្នុង ជំពូកទី ១ មាត្រា ៥ និងមាត្រា ៦ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

ក្រៅពីទទួលរបបសោធននិវត្តន៍ប្រចាំខែ ដូចបានបញ្ជាក់ក្នុងវាក្យខណ្ឌខាងលើ ត្រូវបានទទួលរបបអ្នកនៅក្នុងបន្ទុកដែលរដ្ឋទទួលស្គាល់ ដូចនៅពេលបំរើការងារ ។

**មាត្រា១០.-**

យោធិនអាជីព មុនពេលចូលនិវត្តន៍ អាចអនុញ្ញាតឈប់សម្រាកច្បាប់ ដោយផ្អែកលើករណីចាំបាច់ ដើម្បីប្រុងប្រៀបជីវភាពរស់នៅក្នុងគ្រួសារ ដូចមានចែងក្នុងជំពូកទី ១ មាត្រា ៦ ចំណុច ២ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

-ថ្នាក់ព្រិន្ទបាលឯកចុះ ត្រូវបានឈប់សម្រាក ៦ខែ

-ថ្នាក់នាយចំណង់ និងអនុសេនីយ៍ ត្រូវបានឈប់សម្រាក ៨ខែ

-ថ្នាក់វរសេនីយ៍ ត្រូវបានឈប់សម្រាក ១០ខែ

-ថ្នាក់ឧត្តមសេនីយ៍ ឬវីរជន ត្រូវបានឈប់សម្រាក ១២ខែ ។

នៅពេលឈប់សម្រាកច្បាប់ក្នុងប្រទេស ត្រូវបានទទួលប្រាក់ធ្វើដំណើរ ប្រាក់ហូបចុកតាមផ្លូវទាំងទៅ ទាំងមក តាមប្រកាសកំណត់របស់ក្រសួងការពារជាតិ ។

**មាត្រា១១.-**

យោធិនអាជីព ដែលមានវិន័យ គុណសម្បត្តិ សមត្ថភាព និងសុខភាពល្អ ឬជាអ្នកជំនាញឯកទេស ដែលដល់អាយុកំណត់ចូលនិវត្តន៍ អាចសុំបន្តបំរើការងារ ១ឆ្នាំម្តងៗ ដោយមានការយល់ព្រម ពីរដ្ឋមន្ត្រីក្រសួងការពារជាតិ មានសិទ្ធិដូចខាងក្រោម ÷

១-ទទួលបៀវត្សដូចក្នុងស្ថានភាពសកម្ម

២-រយៈពេលបំរើការងារបន្ត ត្រូវបានគិតក្នុងអតីតភាព ដើម្បីទទួលរបបសោធននិវត្តន៍អតិបរិមា ឬអប្បបរិមា

៣-រយៈពេលសុំបន្តការងារ មិនលើសពី ៥ឆ្នាំឡើយ ។

## ជំពូកទី៣
## របបសោធនបាត់បង់សមត្ថភាពការងារ

**មាត្រា១២.-**

យោធិនអាជីព ដែលអាចទទួលរបបបាត់បង់សមត្ថភាពការងារបានជាប្រចាំខែ លុះត្រាតែបានបំពេញតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ២ មាត្រា ៩ និងមាត្រា ១២ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

អំពីរបៀបគិតរយៈពេលបំរើការងារ ព្រមទាំងការកំណត់តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព គឺត្រូវអនុវត្តតាមការកំណត់ ដូចមានចែងក្នុងជំពូកទី ២ មាត្រា ៧ នៃអនុក្រឹត្យនេះ ។

**មាត្រា១៣.-**

លក្ខខណ្ឌជាក់ស្តែងនៃការកំណត់ប្រភេទកំរិតថ្នាក់បាត់បង់សមត្ថភាពការងារចំពោះយោធិនអាជីព ត្រូវបានកំណត់កំរិតជាបីថ្នាក់ ÷

**ក-កំរិតថ្នាក់ទី១ :**

គឺជាយោធិនអាជីព ដែលបានបំរើការងារ នាំអោយទ្រុឌទ្រោមទាំងស្រុងនៃសរីរាង្គកាយសំខាន់ៗ ។ ជនបាត់បង់សមត្ថភាពការងារ ពុំអាចធ្វើការងារបំរើខ្លួនឯងបាន និងតម្រូវអោយអ្នកដទៃជួយជាអចិន្ត្រៃយ៍ ។ យោធិននេះទទួលបានកំរិតថ្នាក់បាត់បង់សមត្ថភាពការងារ លើសពី ៨០ភាគរយ ។

**ខ-កំរិតថ្នាក់ទី២ :**

គឺជាយោធិនអាជីព ដែលបានបំរើការងារ នាំអោយមានការទ្រុឌទ្រោមធ្ងន់ ឬស្រាលនៃមុខងារសំខាន់ៗរបស់សរីរាង្គកាយ ។ ជនបាត់បង់សមត្ថភាពការងារ អាចប្រកបការងារបាននៅក្នុងករណីពិសេស សាមីជនអាចធានាបានដោយខ្លួនឯងនូវសេចក្តីត្រូវការរបស់ខ្លួនមួយផ្នែកក្នុងជីវភាពប្រចាំថ្ងៃ ដោយមិនចាំបាច់ពឹងផ្អែកជំនួយអចិន្ត្រៃយ៍ពីអ្នកដទៃឡើយ ។ យោធិននេះទទួលបានកំរិតថ្នាក់បាត់បង់សមត្ថភាពការងារ លើសពី ៦០ភាគរយ ។

**គ-កំរិតថ្នាក់ទី៣ :**

គឺជាយោធិនអាជីព ដែលអាចបំរើការងារបាននៅក្នុងករណីដែលបានកំណត់ ដោយមិនចាំបាច់មានអ្នកដទៃជួយនៅក្នុងជីវភាពប្រចាំថ្ងៃឡើយ ។ យោធិននេះ ទទួលបានកំរិតថ្នាក់បាត់បង់សមត្ថភាពការងារលើសពី ៤០ភាគរយ ។

លក្ខខណ្ឌលំអិតជាក់ស្តែង នៃការកំរិតលក្ខណៈបាត់បង់សមត្ថភាពការងារ របស់យោធិនអាជីពទាំងពីរភេទ តាមថ្នាក់នីមួយៗ ត្រូវបានកំណត់ដោយប្រកាសរួមអន្តរក្រសួង របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រា១៤.-**

ប្រាក់សោធនបាត់បង់សមត្ថភាពការងារ រួមមាន បៀវត្សរ៍ឋានន្តរសក្តិ ត្រូវបានបូកបន្ថែមជាមួយប្រាក់ឧបត្ថម្ភលើបៀវត្សរ៍ឋានន្តរសក្តិ បូកប្រាក់ហូបប្រចាំខែ បូកប្រាក់បំណាច់មុខងារ "បើមាន" បូកប្រាក់បំណាច់តំបន់ "បើមាន" ។

**មាត្រា១៥.-**

យោធិនអាជីព ដែលអាចទទួលរបបសោធនបាត់បង់សមត្ថភាពការងារប្រចាំខែបាន លុះត្រាតែបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី២ មាត្រា១២ និងមាត្រា១៣ នៃច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

ក្រៅពីរបបដែលបានបញ្ជាក់ក្នុងវាក្យខណ្ឌខាងលើ យោធិនអាជីពទាំងពីរភេទ អាចទទួលបាននូវរបបអ្នកនៅក្នុងបន្ទុកដែលរដ្ឋទទួលស្គាល់ ដូចនៅពេលបំរើការងារ ។

**មាត្រា១៦.-**

យោធិនអាជីព ដែលមិនមានគ្រប់លក្ខខណ្ឌទទួលរបបសោធនបាត់បង់សមត្ថភាពការងារ ត្រូវទទួលបានរបបចេញពីជួរ ដូចមានចែងក្នុងជំពូកទី២ មាត្រា១១ នៃច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

## ជំពូកទី៤
## សមត្ថកិច្ចនៃការគ្រប់គ្រង និងបើករបបសោធននិវត្តន៍ និងរបបសោធនបាត់បង់សមត្ថភាពការងារ

**មាត្រា១៧.-**

សមត្ថកិច្ចនៃការសំរេចអោយបន្តការងារទៀត ឬសំរេចអោយចូលនិវត្តន៍បាន ដូចមានចែងក្នុងជំពូកទី ១ មាត្រា ៨ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពល

ខេមរភូមិន្ទ ព្រមទាំងអោយទទួលសោធនបាត់បង់សមត្ថភាពការងារ ឬអោយចេញពីជួរ ត្រូវបានកំណត់ដូចខាងក្រោម ÷

១- ដោយព្រះរាជក្រឹត្យ សម្រាប់យោធិនអាជីពថ្នាក់ឧត្តមសេនីយ៍ និងឧត្តមនាវី ។

២-ដោយអនុក្រឹត្យ សម្រាប់យោធិនអាជីពថ្នាក់វរសេនីយ៍ឯក និងវរនាវីឯក ។

៣- ដោយប្រកាសរបស់ក្រសួងការពារជាតិ សម្រាប់យោធិនអាជីពចាប់ពីថ្នាក់វរសេនីយ៍ទោ និងវរនាវីទោចុះ ។

ដើម្បីអនុវត្តឱ្យបានល្អនិងមានប្រសិទ្ធភាព ក្រសួងការពារជាតិត្រូវធ្វើប្រកាស កំណត់អំពីរបៀបគណនាប្រាក់សោធននិវត្តន៍ ប្រាក់សោធនបាត់បង់សមត្ថភាពការងារ និងកំណត់អំពីគំរូបែបបទសំណុំលិខិត នៃការដាក់ឱ្យចូលនិវត្តន៍ ដាក់ឱ្យចូលបាត់បង់សមត្ថភាពការងារ និងដាក់ឱ្យចេញពីជួរ ព្រមទាំងគំរូបែបបទ នៃការស្នើសុំបន្តការងារ នៅពេលដល់អាយុចូលនិវត្តន៍ ។

## មាត្រា១៨.-

ជារៀងរាល់ឆ្នាំ ក្រសួងការពារជាតិត្រូវផ្ញើបញ្ជីឈ្មោះ ភ្ជាប់ជាមួយតួលេខចំនួនទឹកប្រាក់យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពការងារ និងយោធិនចេញពីជួរ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបំរុងថវិកាបើកផ្តល់ប្រាក់សោធននិវត្តន៍ សោធនបាត់បង់ សមត្ថភាពការងារ និងចេញពីជួរ ។

ក្រសួងការពារជាតិ មានភារកិច្ចបើកប្រាក់ឧបត្ថម្ភមួយលើកជូនដល់និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងយោធិនចេញពីជួរ បន្ទាប់មកត្រូវផ្ទេរទៅអោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ក្រោយពីទទួលបាននិវត្តជន ជនបាត់បង់សមត្ថភាពការងារពីក្រសួងការពារជាតិរួចមក ការគ្រប់គ្រង ការបើកចែករបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារប្រចាំខែ និងការបើករបបធានារ៉ាប់រងសង្គម សំរាប់គ្រួសារ ក្រោយមរណភាពរបស់និវត្តជន ឬជនបាត់បង់សមត្ថភាពការងារ ជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រហូតដល់ពេលបង្កើតបេឡាសោធន ។

## មាត្រា១៩.-

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជ្ញាធរមានសមត្ថកិច្ចពិនិត្យលទ្ធភាព ក្នុងការបណ្តុះបណ្តាល និងជួយរកការងារធ្វើអោយនិវត្តជន ជនបាត់បង់សមត្ថភាពការងារ និងអតីតយោធិនចេញពីជួរ ដែលមានលទ្ធភាពធ្វើការងារទៀតបាន ផ្អែកតាមសំណើ និងជំនាញរបស់សាមីខ្លួន ។

## មាត្រា២០.-

យោធិនបាត់បង់សមត្ថភាពការងារ ដែលគ្មានទីបង្អែកដូចមានចែងក្នុងជំពូកទី ២មាត្រា ១៣ (ចំណុច២) នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ រដ្ឋទទួលបន្ទុកយកទៅស្នាក់នៅមជ្ឈមណ្ឌលរបស់រដ្ឋ ឬនិវត្តជនចាស់ជរារស់នៅតែលតោលគ្មានទីបង្អែក ក៏មានសិទ្ធិដូចជន

បាត់បង់សមត្ថភាពដែរ ។

ចំពោះប្រាក់សោធននិវត្តន៍ ឬសោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ត្រូវកាត់យកស្មើនឹង ៥០ភាគរយ ដើម្បីធានាការហូបចុក បើសិនជាខ្វះខាត រដ្ឋបំពេញបន្ថែម ។ ចំពោះយោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី១ បើសិនទៅរស់នៅមជ្ឈមណ្ឌលរបស់រដ្ឋ ប្រាក់ឧបត្ថម្ភសំរាប់អ្នកជំនួយកិច្ចការក្នុងផ្ទះមិនបានបើកផ្តល់អោយឡើយ ។

**មាត្រា២១.-**

និវត្តជន ឬជនបាត់បង់សមត្ថភាពការងារ មានសិទ្ធិស្នើរកពាក់ឯកសណ្ឋានកងយោធពលខេមរភូមិន្ទ ដូចមានចែងក្នុងជំពូកទី ១ មាត្រ ៧ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ដើម្បីជាកិត្តិយសក្នុងពិធីបុណ្យជាតិផ្សេងៗ ។

ការបើកផ្តល់ឯកសណ្ឋានកងយោធពលខេមរភូមិន្ទនេះ ត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

**មាត្រា២២.-**

ក្រោយពេលនិវត្តជន ឬជនបាត់បង់សមត្ថភាពការងារទទួលមរណភាព គ្រួសារទាំងនេះ ត្រូវបានប្រាក់ឧបត្ថម្ភ ដូចមានចែងក្នុងជំពូកទី២ មាត្រា១៤ នៃច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា២៣.-**

អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងអនុក្រឹត្យលេខ ៣២ អនក្រ.បក. ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០០ ស្តីពីវិសោធនកម្មមាត្រា៤ ១៤ និង១៥ នៃអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមិនា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា២៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០០

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ទៀ បាញ់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៤
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## របបគោលនយោបាយចំពោះជនរងគ្រោះស្លាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៦

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះកំណត់អំពីរបបគោលនយោបាយចំពោះជនរងគ្រោះស្លាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ។

មាត្រា ២.-

មជ្ឈមណ្ឌលរបស់រដ្ឋ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

មាត្រា ៣.-

ជនរងគ្រោះទាំងឡាយ ដែលអនុក្រឹត្យនេះសំដៅដល់មានៈ ទារកកំព្រា កុមារកំព្រា កុមារ យុវកុមារ រងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ដោយអំពើទាស់ខុសនឹងច្បាប់ ជនរងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ជនរងគ្រោះដោយសារការជួញដូរមនុស្ស ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ហើយមានលក្ខណវិនិច្ឆ័យ ដូចមានចែងក្នុងមាត្រា ៤ ។

## ជំពូកទី ២
## លក្ខណវិនិច្ឆ័យជនរងគ្រោះ

មាត្រា ៤.-

លក្ខណវិនិច្ឆ័យជនរងគ្រោះ ស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ មានដូចតទៅ ÷

ក-ទារកកំព្រា កុមារកំព្រា ÷

១-ទារកកំព្រា កុមារកំព្រា ដែលមានអាយុ១៥ឆ្នាំចុះ ដែលឪពុកម្តាយស្លាប់ចោល ឬ បោះបង់ចោលដោយប្រការផ្សេងៗ និងគ្មានញាតិសន្តានយកទៅចិញ្ចឹម ។

២-ទារក កុមារ ដែលមានអាយុ១៥ឆ្នាំចុះ រស់នៅក្នុងគ្រួសារទីទ័លក្រ ឬ ពិការបាត់បង់សមត្ថភាពពលកម្ម ហើយគ្មានញាតិសន្តានយកទៅចិញ្ចឹម ។

ខ-កុមារ យុវកុមារ ដែលមានអាយុចាប់ពី ៧ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ រងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ដោយអំពើទាស់ខុសនឹងច្បាប់ ត្រូវបានឪពុកម្តាយ អាណាព្យាបាល អាជ្ញាធរមានសមត្ថកិច្ច មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង បញ្ជូនមកមជ្ឈមណ្ឌលរដ្ឋ ។

គ-ជនដែលរងគ្រោះ ដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ហើយត្រូវបានគ្រួសារ អាជ្ញាធរមានសមត្ថកិច្ច មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង បញ្ជូនមកមជ្ឈមណ្ឌលរដ្ឋ ។

ឃ-ជនដែលរងគ្រោះ ដោយសារការជួញដូរមនុស្ស ហើយត្រូវបានអាជ្ញាធរមានសមត្ថកិច្ច មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង បញ្ជូនមកមជ្ឈមណ្ឌលរដ្ឋ ។

ង-ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង គ្មានជំរក គ្មានសាច់សារលោហិតជួយចិញ្ចឹមថែទាំ គ្មានលទ្ធភាពប្រកបមុខរបរដោយផ្ទាល់ខ្លួន អាចទទួលការស្តារលទ្ធភាពពលកម្ម ឬ ការបណ្តុះបណ្តាលវិជ្ជាជីវៈបាន ។

## ជំពូកទី ៣

## របបគោលនយោបាយចំពោះជនរងគ្រោះ

**មាត្រា ៥.-**

ទារកកំព្រា កុមារកំព្រា កុមារ យុវកុមារ រងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ដោយអំពើទាស់ខុសនឹងច្បាប់ ជនរងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ជនរងគ្រោះដោយសារការជួញដូរមនុស្ស ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង ត្រូវបានទទួលការចិញ្ចឹមបីបាច់ថែទាំ ស្តារលទ្ធភាពពលកម្ម ផ្គត់ផ្គង់ជីវភាព អប់រំ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងត្រូវបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ។

**មាត្រា ៦.-**

ជនរងគ្រោះដូចមានចែងក្នុងមាត្រា ៣ ខាងលើ ត្រូវបានទទួលរបបគោលនយោបាយថែទាំដូចខាងក្រោម ÷

| ល.រ | ប្រភេទមុខសញ្ញា និង កម្រិតអាយុ | ចំនួនមុខសញ្ញា | ចំនួន មេដោះ ឬអ្នកថែទាំ | ប្រភេទបុគ្គលិក |
|---|---|---|---|---|
| ១ | ទារកកំព្រា កុមារកំព្រា | | | |
| ១.១ | អាយុ១ឆ្នាំចុះ | ៣ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ១.២ | អាយុលើសពី ១ឆ្នាំដល់ ៣ឆ្នាំ | ៥ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ១.៣ | អាយុលើសពី ៣ឆ្នាំ | ១០-១៥នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |

| | | | | |
|---|---|---|---|---|
| ១.៤ | ទារកកំព្រា កុមារកំព្រាពិការធ្ងន់ធ្ងរ ឬកើតជំងឺអេដស៍ (AIDS) | ២ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| **២** | **កុមារ យុវកុមារ រងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ដោយអំពើទាស់ខុសនឹងច្បាប់** | | | |
| ២.១ | អាយុពី ៧ឆ្នាំដល់ក្រោម ១៨ឆ្នាំ | ១០ នាក់ | ១នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| **៣** | **ជនរងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់** | | | |
| ៣.១ | អាយុពី ១៨ឆ្នាំឡើង | ១០ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| **៤** | **ជនរងគ្រោះដោយសារការជួញដូរមនុស្ស** | | | |
| ៤.១ | អាយុក្រោម ១៨ឆ្នាំចុះ | ១០ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ៤.២ | អាយុពី ១៨ឆ្នាំឡើង | ១៥ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| **៥** | **ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង** | | | |
| ៥.១ | ជនពិការបាត់បង់សមត្ថភាពពលកម្មគ្មានទីពឹង | ៥ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ៥.២ | ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង | ១៥ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |
| ៥.៣ | ជនពិការទទួលការស្តារលទ្ធភាពពលកម្ម និង បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ | ១៥ នាក់ | ១ នាក់ | មន្ត្រីរាជការឬជាប់កិច្ចសន្យា |

មាត្រា ៧.-

ប្រាក់ឧបត្ថម្ភចំពោះទារកកំព្រា កុមារកំព្រា កុមារ យុវកុមារ រងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ដោយអំពើទាស់ខុសនឹងច្បាប់ ជនរងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ជនរងគ្រោះដោយសារការជួញដូរមនុស្ស ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង មានដូចខាងក្រោម ÷

| ល.រ | ប្រភេទមុខសញ្ញា និង កម្រិតអាយុ | ចំនួនឯកតា ក្នុង ១នាក់ | ប្រាក់ ឧបត្ថម្ភ(៛) | ប្រភេទមុខចំណាយ | កំណត់សំគាល់ |
|---|---|---|---|---|---|
| ១ | *ទារកកំព្រា កុមារកំព្រា ទារក កុមារពិការធ្ងន់ធ្ងរ មានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគ ឬមានជំងឺអេដស៍ (HIV/ AIDS)* | | | | |
| ១.១ | ទារកអាយុ២ឆ្នាំចុះ | ១ខែ | ៦០.០០០៛ | ទឹកដោះគោ | |
| | | ១ដង ក្នុង១ឆ្នាំ | ១២០.០០០៛ | សម្លៀកបំពាក់ សម្ភារៈ ដំណេក អនាម័យ និង ព្យាបាល | ទទួលពេល ដើមឆ្នាំ |
| ១.២ | កុមារអាយុលើសពី ២ឆ្នាំ | ១ខែ | ៤៥.០០០៛ | ម្ហូបអាហារ | |
| | | ១ដង ក្នុង១ឆ្នាំ | ១២០.០០០៛ | សម្លៀកបំពាក់ សម្ភារៈ សិក្សា កីឡា សម្ភារៈ ដំណេក ផ្ទះបាយ អនាម័យ និងព្យាបាល | ទទួលពេល ដើមឆ្នាំ |
| ១.៣ | ទារក កុមារពិការធ្ងន់ធ្ងរមាន ជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ (HIV/AIDS) | ១ខែ | ២០.០០០៛ | បំប៉នសុខភាព | |
| ១.៤ | ទារក កុមារអាយុ៥ឆ្នាំចុះ ទទួលមរណភាព | ១ដងគត់ | ២៧០.០០០៛ | រៀបចំពិធីបុណ្យសព | ស្មើប្រាក់ម្ហូប អាហារ ៦ខែ |
| ១.៥ | កុមារអាយុលើសពី ៥ឆ្នាំឡើង ទទួលមរណភាព | ១ដងគត់ | ៥៤០.០០០៛ | រៀបចំពិធីបុណ្យសព | ស្មើប្រាក់ម្ហូប អាហារ ១២ខែ |
| ១.៦ | អាយុពី ១៨ឆ្នាំ ឡើង | ១ដងគត់ | ១.០៨០.០០០៛ | សមាហរណកម្ម | ស្មើប្រាក់ម្ហូប អាហារ ២៤ខែ |
| ២ | *កុមារ យុវកុមារ រងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ដោយអំពើទាស់ខុសនឹងច្បាប់ និង ជនរងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់* | | | | |

| | | | | | |
|---|---|---|---|---|---|
| ២.១ | កុមារ យុវកុមារអាយុពី ៧ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ និង ជនរងគ្រោះដោយសារការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ | ១ ខែ | ៤៥.០០០៛ | ម្ហូបអាហារ | |
| | | ១ឆ្នាំ | ១២០.០០០៛ | សម្លៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ផ្ទះបាយ អនាម័យ និង ព្យាបាល | ទទួលពេលដើមឆ្នាំ |
| | | ១វគ្គ | ៣៩០.០០០៛ | បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ | រយៈពេលខ្លី ៣ខែ |
| | | ១ដងគត់ | ២២៥.០០០៛ | សមាហរណកម្ម | ស្មើប្រាក់ម្ហូបអាហារ ៥ខែ |
| ៣ | ***ជនរងគ្រោះដោយសារការជួញដូរមនុស្ស*** | | | | |
| ៣.១ | ជនរងគ្រោះដោយសារការជួញដូរមនុស្ស | ១ខែ | ៤៥.០០០៛ | ម្ហូបអាហារ | |
| | | ១ឆ្នាំ | ១២០.០០០៛ | សម្លៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ផ្ទះបាយ អនាម័យ និង ព្យាបាល | ទទួលពេលដើមឆ្នាំ |
| | | ១វគ្គ | ៣៩០.០០០៛ | បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ | រយៈពេលខ្លី ៣ខែ |
| | | ១ដងគត់ | ៨១០.០០០៛ | សមាហរណកម្ម | ស្មើប្រាក់ម្ហូបអាហារ ១៨ខែ |
| ៤ | ***ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង*** | | | | |
| ៤.១ | ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង | ១ខែ | ៤៥.០០០៛ | ម្ហូបអាហារ | |
| | | ១ឆ្នាំ | ១២០.០០០៛ | សម្លៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ផ្ទះបាយ អនាម័យ និង ព្យាបាល | ទទួលពេលដើមឆ្នាំ |

| | | | | | |
|---|---|---|---|---|---|
| ៤.២ | ជនពិការបាត់បង់សមត្ថភាពពលកម្មធ្ងន់ធ្ងរ ជនអនាថា ជនចាស់ជរាគ្មានទីពឹង និង ជនពិការមាន ជំងឺអេដស៍ (AIDS) | ១ខែ | ២០,០០០៛ | ប័ណ្ណសុខភាព | |
| ៤.៣ | ជនពិការអនាថាដែលមាន ជំងឺអេដស៍ (AIDS) | ១វគ្គ | ៣៩០,០០០៛ | បណ្តុះបណ្តាលមុខជំនាញ វិជ្ជាជីវៈ | រយៈពេលខ្លី ៣ខែ |
| ៤.៤ | ជនពិការ ជនអនាថា និងជនចាស់ជរាគ្មានទីពឹងទទួល មរណភាព | ១ដងគត់ | ៥៤០,០០០៛ | រៀបចំពិធីបុណ្យសព | ស្មើប្រាក់ម្ហូបអាហារ ១២ខែ |
| ៤.៥ | ជនពិការ ជនអនាថា និង ជនចាស់ជរាគ្មានទីពឹង | ១ដងគត់ | ៨១០,០០០៛ | សមាហរណកម្ម | ស្មើប្រាក់ម្ហូបអាហារ ១៨ខែ |

មាត្រា ៨.-

នីតិវិធី និងសំណុំលិខិតនៃការបញ្ចូល បញ្ចេញ និងធ្វើសមាហរណកម្មជនរងគ្រោះ ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

មាត្រា ៩.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៧

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ សេចក្តីសំរេចរបស់ក្រុមប្រឹក្សារាជសម្បត្តិ លេខ គរស/សសរ/១០០៤/០០១ ចុះថ្ងៃ ១៤ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការជ្រើសរើសព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់ពេលវេលាបំរើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

## ស ម្រេ ច

**មាត្រា ១.-**

អនុញ្ញាតឱ្យមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជា បានឈប់សម្រាកការងារឆ្នាំ ២០០៧ តាមប្រតិទិន ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| - ថ្ងៃទី ០១ | មករា | ទិវាចូលឆ្នាំសកល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៧ | មករា | ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០២ | កុម្ភៈ | ពិធីបុណ្យមាឃបូជា | សម្រាក ០១ ថ្ងៃ |

Anukrit-06

| | | | | |
|---|---|---|---|---|
| - | ថ្ងៃទី ០៨ | មីនា | ទិវានារីអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - | ថ្ងៃទី ១៤-១៥-១៦ | មេសា | ពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ | សម្រាក ០៣ ថ្ងៃ |
| - | ថ្ងៃទី ០១ | ឧសភា | ទិវាពលកម្មអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - | ថ្ងៃទី ០១ | ឧសភា | ពិធីបុណ្យវិសាខបូជា | សម្រាក ០១ ថ្ងៃ |
| - | ថ្ងៃទី ០៥ | ឧសភា | ព្រះរាជពិធីច្រត់ព្រះនង្គ័ល | សម្រាក ០១ ថ្ងៃ |
| - | ថ្ងៃទី ១៣-១៤-១៥ | ឧសភា | ព្រះរាជពិធីបុណ្យចំរើនព្រះជន្មព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា | សម្រាក ០៣ ថ្ងៃ |
| - | ថ្ងៃទី ១៨ | មិថុនា | ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា **នរោត្តម មុនិនាថ សីហនុ** | សម្រាក ០១ ថ្ងៃ |
| - | ថ្ងៃទី ២៤ | កញ្ញា | ទិវាប្រកាសរដ្ឋធម្មនុញ្ញ | សម្រាក ០១ ថ្ងៃ |
| - | ថ្ងៃទី ១០-១១-១២ | តុលា | ពិធីបុណ្យភ្ជុំបិណ្ឌ | សម្រាក ០៣ ថ្ងៃ |
| - | ថ្ងៃទី ២៩ | តុលា | ព្រះរាជពិធីគ្រងរាជសម្បត្តិរបស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា | សម្រាក ០១ ថ្ងៃ |
| - | ថ្ងៃទី ៣១ | តុលា | ព្រះរាជពិធីបុណ្យចំរើនព្រះជន្មព្រះវររាជបិតា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** | សម្រាក ០១ ថ្ងៃ |
| - | ថ្ងៃទី ០៩ | វិច្ឆិកា | ពិធីបុណ្យឯករាជ្យជាតិ | សម្រាក ០១ ថ្ងៃ |
| - | ថ្ងៃទី ២៣-២៤-២៥ | វិច្ឆិកា | ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក | សម្រាក ០៣ ថ្ងៃ |
| - | ថ្ងៃទី ១០ | ធ្នូ | ទិវាសិទ្ធិមនុស្សអន្តរជាតិ | សម្រាក ០១ ថ្ងៃ |

**មាត្រា ២.-**

ពេលវេលាឈប់សម្រាកទាំងឡាយណាដែលត្រូវចំថ្ងៃណាមួយនៃថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ (សៅរ៍ ឬ អាទិត្យ) ត្រូវបានឱ្យឈប់ចំនួន ០១ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត។ ប៉ុន្តែ ក្នុងករណីត្រូវចំទាំងពីរថ្ងៃជាប់គ្នា គឺទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវអនុញ្ញាតអោយឈប់សម្រាកបន្ថែមជាជំនួស គឺឈប់ចំនួន ០១ ថ្ងៃតែប៉ុណ្ណោះ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ១០ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- **ក្រសួងព្រះបរមរាជវាំង**
- **អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
- **អគ្គលេខាធិការដ្ឋានរដ្ឋសភា**
- **ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី**
- **ដូចមាត្រា៤**
- **ឯកសារ កាលប្បវត្តិ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១០៩៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

១- វរសេនីយ៍ទោ **ហ៊ុល សំអុន** អត្តលេខ ០០៩១០៧ ជំនួយការ ឯកឧត្តម ម៉ុង សំផន

២- វរសេនីយ៍ទោ **តុប វណ្ណា** អត្តលេខ ០១៧២០១ ជំនួយការ ឯកឧត្តម នាង ផាត

៣- វរសេនីយ៍ទោ **មាស សាឈាស់** អត្តលេខ ០០២៣១៥ ជំនួយការ ឯកឧត្តម ហាក់ សាវុធ

៤- វរសេនីយ៍ទោ **សំ ចាន់ធួន** អត្តលេខ ០១៣៩៩៨ ជំនួយការ ឯកឧត្តម អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា

៥- វរសេនីយ៍ទោ អ៊ុច ម៉ូរ៉ាមី អត្តលេខ ០១៩៥៦៤ ជំនួយការ ឯកឧត្តម អគ្គលេខាធិការ ក្រសួងការពារជាតិ

៦- វរសេនីយ៍ទោ សួន យុន្ធទូ អត្តលេខ ០១៤៥៤៤ នាយការិយាល័យគ្រប់គ្រង និងបណ្តុះបណ្តាល ជំនាញឯកទេស នាយកដ្ឋានបំពាក់សំភារៈសឹក

៧- វរសេនីយ៍ទោ ស្រី ថាវរិទ្ធ អត្តលេខ ០០៨៤៦១ នាយការិយាល័យភស្តុភារ-ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ

៨- វរសេនីយ៍ទោ ម៉ុន សំ អត្តលេខ ០០១៤៣៨ នាយលេខាធិការដ្ឋាន នាយកដ្ឋានផ្គត់ផ្គង់

៩- វរសេនីយ៍ទោ ម៉ៅ សុគន្ធ អត្តលេខ ០០៨៣៧៣ ជំនួយការ ឯកឧត្តមអគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ

១០- វរសេនីយ៍ទោ ជា សារិទ្ធ អត្តលេខ ០០៨៣៨០ នាយអង្គភាពកាត់ដេរ នាយកដ្ឋានផ្គត់ផ្គង់

១១- វរសេនីយ៍ទោ ពិន ពៅ អត្តលេខ ០១៣៨៩៩ នាយអង្គភាពផលិតស្បៀងក្រៀម នាយកដ្ឋានផ្គត់ផ្គង់

១២- វរសេនីយ៍ទោ យឹម ហោច អត្តលេខ ០០១៤៥២ នាយអង្គភាពឃ្លាំងស្បៀង នាយកដ្ឋានផ្គត់ផ្គង់

១៣- វរសេនីយ៍ទោ អ៊ុន សារុំ អត្តលេខ ០០១៤៦៥ នាយការិយាល័យ ពលីពិការ នាយកដ្ឋានកិច្ចការយោធាស៊ីវិល

១៤- វរសេនីយ៍ទោ ម៉ុន គារី អត្តលេខ ០១៤៣៨១ នាយអគារមុខសាស្រ្ត មន្ទីរពេទ្យព្រះកេតុ មាលា

១៥- វរសេនីយ៍ទោ ម៉ុច ចាន់តារា អត្តលេខ ០០១៧៩១ នាយអគារវះកាត់ពោះ ទ្រូង មន្ទីរពេទ្យ ព្រះកេតុមាលា

១៦- វរសេនីយ៍ទោ ញ៉ឹម សំបូន អត្តលេខ ០០៩៤៦៣ ជំនួយការ ឯកឧត្តម ឈុំ សុជាតិ

១៧- វរសេនីយ៍ទោ អោក ពិន អត្តលេខ ០១២៩៦៦ នាយលេខាធិការដ្ឋាន ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន

១៨- វរសេនីយ៍ទោ លី គត្តី អត្តលេខ ០០៣២៣៤ នាយករង ទីចាត់ការហិរញ្ញវត្ថុ អគ្គបញ្ជាការដ្ឋាន

១៩- វរសេនីយ៍ទោ ស៊ឹម តៃ អត្តលេខ ០០១៤០២ នាយរងអធិការកិច្ច កងទ័ពជើងគោក

២០- វរសេនីយ៍ទោ នៀ ម៉ុនធឿន អត្តលេខ ០០៤៩៤៨ មេបញ្ជាការរង និងជានាយសេនាធិការ កងពលតូចថ្មើរជើងលេខ ១២ កងទ័ពជើងគោក

២១- វរសេនីយ៍ទោ ធុក ធារីវុឌ្ឍ អត្តលេខ ០០៣៨៣០ នាយរងអធិការកិច្ច កងទ័ពជើងគោក

២២- វរសេនីយ៍ទោ អ៊ាច ឡៃ អត្តលេខ ០០២១៨០ ជំនួយការផ្ទាល់ ឯកឧត្តម គន់ គីម អគ្គមេបញ្ជាការរង

២៣- វរសេនីយ៍ទោ គៀង គីមអាន អត្តលេខ ០០១៨៤៨ លេខាផ្ទាល់ ឯកឧត្តម គន់ គីម អគ្គមេប ញ្ជាការរង

២៤- វរសេនីយ៍ទោ ស៊ឹម ស៊ុនធីម អត្តលេខ ០០១២៥៧ ជំនួយការទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រី

២៥- វរសេនីយ៍ទោ ញ៉ឹម សារីម អត្តលេខ ០០៥២៩២ ជំនួយការ ឯកឧត្តម គន់ គីម

២៦- វរសេនីយ៍ទោ ម៉េង ស៊ុនណា អត្តលេខ ០០៨៩១៩ នាយការិយាល័យអធិការកិច្ចជើងអាកាស អធិការដ្ឋាន

២៧- វរសេនីយ៍ទោ ស៊ុយ ចាន់យ៉ីពុន អត្តលេខ ០០២៤៥៦ នាយលេខាធិការដ្ឋាន សេនាធិការដ្ឋានអន្ត រាគមន៍

២៨- វរសេនីយ៍ទោ នី ស្រ៉ាច អត្តលេខ ០០២១៦៤ នាយការិយាល័យឃោសនាពត៌មាន សេនា ធិការដ្ឋានអន្តរាគមន៍

| | | | | | |
|---|---|---|---|---|---|
| ២៩- វរសេនីយ៍ទោ | អ៊ិន | សីហៈ | អត្តលេខ ០០៣២៣៩ | នាយការិយាល័យបូកសរុប | ទីចាត់ការកលយុទ្ធ |
| ៣០- វរសេនីយ៍ទោ | ផន | ផល | អត្តលេខ ០០៨៩៨៨ | នាយករង | ទីចាត់ការផែនការ |
| ៣១- វរសេនីយ៍ទោ | ពេជ្រ | គល្យាណ | អត្តលេខ ០០៣៨៣៩ | នាយករង | ទីចាត់ការ ការពារតីមីសាស្ត្រ |
| ៣២- វរសេនីយ៍ទោ | គឹម | អ៊ីវ៉ា | អត្តលេខ ០០៩១០៤ | នាយករង | ទីចាត់ការ ការពារតីមីសាស្ត្រ |
| ៣៣- វរសេនីយ៍ទោ | ម៉ែន | វ៉ាទី | អត្តលេខ ០១០១៧៥ | នាយការិយាល័យស្រាវជ្រាវជើងគោកមជ្ឈមណ្ឌល ស្រាវជ្រាវយុទ្ធសាស្ត្រយោធា | |
| ៣៤- វរសេនីយ៍ទោ | ខាន់ | រស់ | អត្តលេខ ០០២០៩៩ | នាយកសាលា | បញ្ជាការដ្ឋានកាំភ្លើងធំ |
| ៣៥- វរសេនីយ៍ទោ | ជុំ | សុវណ្ណារ៉ា | អត្តលេខ ០០៩០៨០ | នាយការិយាល័យប្រតិបត្តិការ | បញ្ជាការដ្ឋានបញ្ជូនសារ |
| ៣៦- វរសេនីយ៍ទោ | ជុំ | ជាទី | អត្តលេខ ០០២២៨០ | នាយការិយាល័យហ្វឹកហ្វឺន | បញ្ជាការដ្ឋានបញ្ជូនសារ |
| ៣៧- វរសេនីយ៍ទោ | ទឹម | សុផល | អត្តលេខ ០០៩០៨១ | នាយការិយាល័យបច្ចេកទេស | បញ្ជាការដ្ឋានបញ្ជូនសារ |
| ៣៨- វរសេនីយ៍ទោ | ឌូ | គុន | អត្តលេខ ០០២៤៣៩ | មេបញ្ជាការរង | បញ្ជាការដ្ឋានការពារអាកាស |
| ៣៩- វរសេនីយ៍ទោ | ហ៊្វាំ | សុខន | អត្តលេខ ០០២៤៥២ | នាយសេនាធិការរង | បញ្ជាការដ្ឋានការពារអាកាស |
| ៤០- វរសេនីយ៍ទោ | ជុំ | ណារុន | អត្តលេខ ០០៨៩៧៣ | នាយរង ខុទ្ទកាល័យ បញ្ជាការដ្ឋាន | កងទ័ពជើងគោក |
| ៤១- វរសេនីយ៍ទោ | អៀច | សុវណ្ណថា | អត្តលេខ ០០១៨៥០ | នាយរង ខុទ្ទកាល័យ បញ្ជាការដ្ឋាន | កងទ័ពជើងគោក |
| ៤២- វរសេនីយ៍ទោ | អ៊ុច | សារិន | អត្តលេខ ០០១៨៥៤ | នាយរង អធិការកិច្ច បញ្ជាការដ្ឋាន | កងទ័ពជើងគោក |
| ៤៣- វរសេនីយ៍ទោ | រស់ | តិរុណ | អត្តលេខ ០០១៩៣១ | នាយរង អធិការកិច្ច បញ្ជាការដ្ឋាន | កងទ័ពជើងគោក |
| ៤៤- វរសេនីយ៍ទោ | ចំនួ | មុន្នី | អត្តលេខ ០០១៨៦០ | នាយរង អធិការកិច្ច បញ្ជាការដ្ឋាន | កងទ័ពជើងគោក |
| ៤៥- វរសេនីយ៍ទោ | យិន | ទុន្តា | អត្តលេខ ០០១៨៦២ | នាយរង ការិយាល័យហ្វឹកហ្វឺន | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៤៦- វរសេនីយ៍ទោ | ខេង | ប៊ុនឡុង | អត្តលេខ ០០២២១៥ | នាយរង ការិយាល័យហ្វឹកហ្វឺន | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៤៧- វរសេនីយ៍ទោ | ឆាយ | សារី | អត្តលេខ ០០៤១១៨ | នាយរង ការិយាល័យទី ១ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៤៨- វរសេនីយ៍ទោ | ណុប | សុវណ្ណមុនី | អត្តលេខ ០០៣៤៧២ | នាយរង ការិយាល័យទី ១ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៤៩- វរសេនីយ៍ទោ | ខាច់ | ចាន់តារ៉ា | អត្តលេខ ០០០៦៦២ | នាយរង ការិយាល័យទី ២ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៥០- វរសេនីយ៍ទោ | គន់ | សារ៉ាត់ | អត្តលេខ ០០២១៧៥ | នាយរង ការិយាល័យទី ២ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៥១- វរសេនីយ៍ទោ | ខេង | ចាន់រិទ្ធ | អត្តលេខ ០០៤១៣២ | នាយរង ការិយាល័យទី ២ | កងទ័ពជើងគោក |
| ៥២- វរសេនីយ៍ទោ | ផេង | ភក្តី | អត្តលេខ ០០១៩១៨ | នាយរង ការិយាល័យទី ២ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៥៣- វរសេនីយ៍ទោ | ឈិន | រាមា | អត្តលេខ ០០០៦៥៨ | នាយរង ការិយាល័យទី ៣ | បញ្ជាការដ្ឋានកងទ័ពជើងគោក |

| | | | | | |
|---|---|---|---|---|---|
| ៥៤- វរសេនីយ៍ទោ | ស៊ិន | ចំន្ទរិទ្ធី | អត្តលេខ ០០១២២១ | នាយរង ការិយាល័យទី ៣ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៥៥- វរសេនីយ៍ទោ | លុយ | សារមធ | អត្តលេខ ០០៣២៣៨ | នាយរង ការិយាល័យទី ៣ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៥៦- វរសេនីយ៍ទោ | ឡុក | ឈី | អត្តលេខ ០០៤១៣៥ | នាយរង ការិយាល័យទី ៣ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៥៧- វរសេនីយ៍ទោ | ពុធ | យន | អត្តលេខ ០០៤១៤០ | នាយរង ការិយាល័យទី ៣ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៥៨- វរសេនីយ៍ទោ | ម៉ែច | ចាន់ធី | អត្តលេខ ០០១៩៨០ | នាយរង ការិយាល័យទី ៤ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៥៩- វរសេនីយ៍ទោ | តែ | សុខឈន់ | អត្តលេខ ០០១៩៨៣ | នាយរង ការិយាល័យទី ៤ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៦០- វរសេនីយ៍ទោ | ឌី | គា | អត្តលេខ ០០១៩៩០ | នាយរង ការិយាល័យទី ៤ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៦១- វរសេនីយ៍ទោ | ស៊ីម | សំអាត | អត្តលេខ ០០៨៧៩៨ | នាយរង ការិយាល័យទី ៤ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៦២- វរសេនីយ៍ទោ | ម៉ុ | នរិទ្ធ | អត្តលេខ ០០២០៨០ | នាយរង ការិយាល័យទី ៥ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៦៣- វរសេនីយ៍ទោ | ប៉ែន | យឿន | អត្តលេខ ០០៤១២០ | នាយរង ការិយាល័យទី ៥ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៦៤- វរសេនីយ៍ទោ | សុខ | សត្ថា | អត្តលេខ ០០២០២៩ | នាយរង ការិយាល័យទី ៥ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៦៥- វរសេនីយ៍ទោ | ចែ | សំអូន | អត្តលេខ ០០១៩៩៦ | នាយរង ការិយាល័យទី ៥ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៦៦- វរសេនីយ៍ទោ | ស៊ុយ | សឿន | អត្តលេខ ០០២០១៤ | នាយរង ការិយាល័យទី ៥ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៦៧- វរសេនីយ៍ទោ | គីម | ឆាន | អត្តលេខ ០០២០០៣ | នាយរង ការិយាល័យទី ៥ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៦៨- វរសេនីយ៍ទោ | កែវ | គីមសៀង | អត្តលេខ ០០០៦៩៣ | នាយរង ការិយាល័យយោធាតំបន់ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៦៩- វរសេនីយ៍ទោ | ប្រាក់ | សូសៀង | អត្តលេខ ០០០៦៩៨ | នាយរង ការិយាល័យយោធាតំបន់ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៧០- វរសេនីយ៍ទោ | មុំ | ពូន | អត្តលេខ ០០០៦៩៧ | នាយរង ការិយាល័យយោធាតំបន់ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៧១- វរសេនីយ៍ទោ | កែវ | ចាន់នី | អត្តលេខ ០០០៩៧១ | នាយរង ការិយាល័យយោធាតំបន់ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៧២- វរសេនីយ៍ទោ | នួន | ចែម | អត្តលេខ ០០៤៦៣៣ | នាយរង ការិយាល័យយោធាតំបន់ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៧៣- វរសេនីយ៍ទោ | ឈែម | អ៊ែត | អត្តលេខ ០០២៥១៧ | នាយរង ការិយាល័យយោធាតំបន់ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៧៤- វរសេនីយ៍ទោ | ឌេព | ចន្នី | អត្តលេខ ០០២០៤៦ | នាយរង ការិយាល័យយោធាតំបន់ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៧៥- វរសេនីយ៍ទោ | សុខ | នារី | អត្តលេខ ០០២០៤៧ | នាយរង ការិយាល័យយោធាតំបន់ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៧៦- វរសេនីយ៍ទោ | គង់ | សារ៉ែន | អត្តលេខ ០០០៧២៦ | នាយរងការិយាល័យអភិវឌ្ឍន៍ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៧៧- វរសេនីយ៍ទោ | សៅ | ចាន់ | អត្តលេខ ០០០៦៤៤ | នាយរងការិយាល័យអភិវឌ្ឍន៍ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៧៨- វរសេនីយ៍ទោ | អ៊ុច | ប៊ុន | អត្តលេខ ០០៣៦២៣ | នាយរងការិយាល័យអភិវឌ្ឍន៍ | បញ្ជាការដ្ឋានកងទ័ពជើងគោក |

| | | | | | |
|---|---|---|---|---|---|
| ៧៩- វរសេនីយ៍ទោ | សេក | យ៉ោន | អត្តលេខ ០០២០៦៤ | នាយរងការិយាល័យអភិវឌ្ឍន៍ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៨០- វរសេនីយ៍ទោ | ឆាង | គឹមតិច | អត្តលេខ ០១០៤៣១ | នាយរងការិយាល័យអភិវឌ្ឍន៍ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៨១- វរសេនីយ៍ទោ | គង់ | សំណាង | អត្តលេខ ០០២៨៣៧ | នាយរងការិយាល័យអភិវឌ្ឍន៍ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៨២- វរសេនីយ៍ទោ | គង់ | សារ៉ាន់ | អត្តលេខ ០០៣២៤១ | នាយរងការិយាល័យអភិវឌ្ឍន៍ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៨៣- វរសេនីយ៍ទោ | ទ្រី | គង់ | អត្តលេខ ០០២០៦៧ | នាយរងការិយាល័យអភិវឌ្ឍន៍ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៨៤- វរសេនីយ៍ទោ | ស្វាយ | សុធី | អត្តលេខ ០១១៣៩៩ | នាយរងការិយាល័យអភិវឌ្ឍន៍ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៨៥- វរសេនីយ៍ទោ | ឆាយ | ចន្ថា | អត្តលេខ ០០៣១៩២ | នាយរងការិយាល័យការពារព្រំដែន | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៨៦- វរសេនីយ៍ទោ | ហ៊ុន | ឡេខជា | អត្តលេខ ០០៣៤១៧ | នាយរងការិយាល័យការពារព្រំដែន | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៨៧- វរសេនីយ៍ទោ | ខៀវ | យ៉ុខ | អត្តលេខ ០០០៧៧៩ | នាយរងការិយាល័យបច្ចេកទេស | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៨៨- វរសេនីយ៍ទោ | សាន | ញ៉ឹម | អត្តលេខ ០០៩០២៦ | នាយរងការិយាល័យបច្ចេកទេស | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៨៩- វរសេនីយ៍ទោ | អ៊ុន | មុន្នី | អត្តលេខ ០០៩០៣៩ | នាយរងការិយាល័យបច្ចេកទេស | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៩០- វរសេនីយ៍ទោ | ម៉ា | វ៉ាន់ធី | អត្តលេខ ០០៩០៤៣ | នាយរងការិយាល័យបច្ចេកទេស | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៩១- វរសេនីយ៍ទោ | គង | សំអួន | អត្តលេខ ០១០៥៥៩ | នាយរងការិយាល័យបច្ចេកទេស | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៩២- វរសេនីយ៍ទោ | ឡាច | សារម៉េត | អត្តលេខ ០០៩០០១ | នាយរងការិយាល័យសុខាភិបាល | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៩៣- វរសេនីយ៍ទោ | កៅ | ទុធ | អត្តលេខ ០០២៧៤៧ | នាយរងការិយាល័យសុខាភិបាល | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៩៤- វរសេនីយ៍ទោ | សោម | សោភ័ណ្ឌ | អត្តលេខ ០០៩២៤៨ | នាយរងការិយាល័យសុខាភិបាល | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៩៥- វរសេនីយ៍ទោ | ហ៊ឹម | គុយ | អត្តលេខ ០០១៨៦៨ | នាយរងការិយាល័យសុខាភិបាល | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៩៦- វរសេនីយ៍ទោ | សាយ | សម្បត្តិ | អត្តលេខ ០០៤១០៨ | នាយរងការិយាល័យបំភន្លឺអក្ខរៈ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៩៧- វរសេនីយ៍ទោ | នួលាស់ | ម៉ាន | អត្តលេខ ០០១៩១២ | នាយរងការិយាល័យបំភន្លឺអក្ខរៈ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៩៨- វរសេនីយ៍ទោ | ខួន | សំអោក | អត្តលេខ ០០២២៤៨ | នាយរងការិយាល័យបំភន្លឺអក្ខរៈ | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៩៩- វរសេនីយ៍ទោ | ទឹម | ធិញ | អត្តលេខ ០០៣៤០២ | មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ១០០- វរសេនីយ៍ទោ | កែវ | ចិបុល | អត្តលេខ ០០៣៤៤៧ | មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម | បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ១០១- វរសេនីយ៍ទោ | សៅ | សារ៉ី | អត្តលេខ ០០២១៥៥ | មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម | បញ្ជាការដ្ឋានកងទ័ពជើងគោក |

១០២- វរសេនីយ៍ទោ ម៉ៅ សារុធ អត្តលេខ ០០២៨០៥ មេបញ្ជាការរង បញ្ជាការដ្ឋានរថក្រោះ បញ្ជាការដ្ឋានកងទ័ពជើងគោក

១០៣- វរសេនីយ៍ទោ គោគ សារូ អត្តលេខ ០០៤១៣៤ មេបញ្ជាការរង បញ្ជាការដ្ឋានរថក្រោះ បញ្ជាការដ្ឋានកងទ័ពជើងគោក

១០៤- វរសេនីយ៍ទោ យិន ចណ្ណា អត្តលេខ ០០១២២២ មេបញ្ជាការរង បញ្ជាការដ្ឋានកាំភ្លើងធំ បញ្ជាការដ្ឋានកងទ័ពជើងគោក

១០៥- វរសេនីយ៍ទោ ផាន់ សាខន អត្តលេខ ០០៤១៥៤ មេបញ្ជាការរង បញ្ជាការដ្ឋានកាំភ្លើងធំ បញ្ជាការដ្ឋានកងទ័ពជើងគោក

១០៦- វរសេនីយ៍ទោ មាន យី អត្តលេខ ០០២១០០ មេបញ្ជាការរង និងជានាយសេនាធិការ បញ្ជាការដ្ឋានកាំភ្លើងធំ

១០៧- វរសេនីយ៍ទោ ពេជ្រ សុផា អត្តលេខ ០០០៨៤៧ មេបញ្ជាការរង បញ្ជាការដ្ឋានការពារអាកាស បញ្ជាការដ្ឋានកងទ័ពជើងគោក

១០៨- វរសេនីយ៍ទោ ព្រុំ ថាវី អត្តលេខ ០០០៨៤៨ មេបញ្ជាការរង បញ្ជាការដ្ឋានការពារអាកាស បញ្ជាការដ្ឋានកងទ័ពជើងគោក

១០៩- វរសេនីយ៍ទោ គង់ សុខុម អត្តលេខ ០០២០៥៨ មេបញ្ជាការរង បញ្ជាការដ្ឋានការពារអាកាស បញ្ជាការដ្ឋានកងទ័ពជើងគោក

១១០- វរសេនីយ៍ទោ អ៊ុក សុផារត អត្តលេខ ០០២៤៥៥ មេបញ្ជាការរង បញ្ជាការដ្ឋានការពារអាកាស បញ្ជាការដ្ឋានកងទ័ពជើងគោក

១១១- វរសេនីយ៍ទោ អៀវ ហុច អត្តលេខ ០០២៤៥៣ មេបញ្ជាការរង បញ្ជាការដ្ឋានការពារអាកាស បញ្ជាការដ្ឋានកងទ័ពជើងគោក

១១២- វរសេនីយ៍ទោ តឹក សារិន អត្តលេខ ០០២១៧០ មេបញ្ជាការរង និងជានាយសេនាធិការ បញ្ជាការដ្ឋានកងទ័ពជើងគោក

១១៣- វរសេនីយ៍ទោ សួស សុទ្ធ អត្តលេខ ០០២២៧៨ មេបញ្ជាការរង បញ្ជាការដ្ឋានបញ្ជូនសារ បញ្ជាការដ្ឋានកងទ័ពជើងគោក

១១៤- វរសេនីយ៍ទោ ចាន់ សេដ្ឋា អត្តលេខ ០០៤១៥១ មេបញ្ជាការរង បញ្ជាការដ្ឋានបញ្ជូនសារ បញ្ជាការដ្ឋានកងទ័ពជើងគោក

១១៥- វរសេនីយ៍ទោ ម៉ូ ចណ្ណារក្ស អត្តលេខ ០០២១៧៤ មេបញ្ជាការរង បញ្ជាការដ្ឋានបញ្ជូនសារ បញ្ជាការដ្ឋានកងទ័ពជើងគោក

១១៦- វរសេនីយ៍ទោ សៅ សារឿន អត្តលេខ ០០៤៦៣ មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម បញ្ជាការដ្ឋានកងទ័ពជើងគោក

១១៧- វរសេនីយ៍ទោ ឡុង គីន អត្តលេខ ០០៣០៥៤ មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ ២១ យោធភូមិភាគទី ២

១១៨- វរសេនីយ៍ទោ មាស ចន្ទគីរី អត្តលេខ ០០០៩៤៥ នាយសេនាធិការរង យោធភូមិភាគទី ៣

១១៩- វរសេនីយ៍ទោ សុខ សាម៉ុន អត្តលេខ ០០០៩៦៧ នាយតំបន់អភិវឌ្ឍន៍ យោធភូមិភាគទី ៤

១២០- វរសេនីយ៍ទោ សុខ សារឿន អត្តលេខ ០០៤៥៨៧ មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ ៤២ យោធភូមិភាគទី ៤

១២១- វរសេនីយ៍ទោ ម៉ែន ឆាន អត្តលេខ ០០០៧៧៤ មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ ៥២ យោធភូមិភាគទី ៥

១២២- វរសេនីយ៍ទោ ឡោ សារឿន អត្តលេខ ០០៣០១៥ មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ ៥៣ យោធភូមិភាគទី ៥

១២៣- វរសេនីយ៍ទោ ហោខ សុផល អត្តលេខ ០០០៨៥៨ នាយតំបន់អភិវឌ្ឍន៍ យោធភូមិភាគពិសេស

១២៤- វរសេនីយ៍ទោ សូ សំអុល អត្តលេខ ០០២៤២៨ នាយការិយាល័យទី ៥ បញ្ជាការដ្ឋាន កងទ័ពជើងអាកាស

១២៥- វរសេនីយ៍ទោ គខ ម៉ិន អត្តលេខ ០០២៤៦២ នាយការិយាល័យបំពាក់អក្ខរៈ បញ្ជាការដ្ឋាន កងទ័ពជើងអាកាស

១២៦- វរសេនីយ៍ទោ គីម សំរេច អត្តលេខ ០០២៤៦៩ នាយរោងជាង បញ្ជាការដ្ឋាន កងទ័ពជើងអាកាស

១២៧- វរសេនីយ៍ទោ ម៉ក់ សុធា អត្តលេខ ០០០៨៣៨ នាយករងសាលាហ្វឹកហ្វឺន បញ្ជាការដ្ឋាន កងទ័ពជើងអាកាស

១២៨- វរសេនីយ៍ទោ សុខ វណ្ណសាន អត្តលេខ ០០២៤៣៧ មេបញ្ជាការរង មូលដ្ឋានពោធិចិនតុង បញ្ជាការដ្ឋានកងទ័ពជើងអាកាស

១២៩- វរសេនីយ៍ទោ សូ មិន អត្តលេខ ០០២៤៣២ មេបញ្ជាការរង មូលដ្ឋានពោធិចិនតុង បញ្ជាការដ្ឋានកងទ័ពជើងអាកាស

១៣០- វរសេនីយ៍ទោ កៅ យាន អត្តលេខ ០០២៤៥៩ មេបញ្ជាការរង មូលដ្ឋានកំពង់ឆ្នាំង បញ្ជាការដ្ឋានកងទ័ពជើងអាកាស

១៣១- វរសេនីយ៍ទោ ហោខ ហ៊ិន អត្តលេខ ០០២៤១៩ មេបញ្ជាការរង មូលដ្ឋានកំពង់ឆ្នាំង បញ្ជាការដ្ឋានកងទ័ពជើងអាកាស

១៣២- វរសេនីយ៍ទោ ចៅ គុម អត្តលេខ ០០៣៤៥៧ មេបញ្ជាការរង មូលដ្ឋានកំពង់ឆ្នាំង បញ្ជាការដ្ឋានកងទ័ពជើងអាកាស

១៣៣- វរសេនីយ៍ទោ អ៊ុក ម៉ុណ្ណារ៉ា អត្តលេខ ០០២៤៩១ មេបញ្ជាការរង កងហោះឧទ្ធម្ភាគចក្រ បញ្ជាការដ្ឋានកងទ័ពជើងអាកាស

